# ប្តី

ពាក្យកាព្យជាព្រះរាជនិពន្ធនៃ ព្រះបាទសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ (ព្រះអង្គដួង) ដែលទ្រង់និពន្ធចប់ស្រេចនៅថ្ងៃសៅរ៍៨រោចខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៣៨០ កាលព្រះអង្គមានព្រះជន្មគម្រប់ ៤១ វស្សា, យើងស្រង់ព្រះរាជនិពន្ធនោះយកមកទុកជាព្រះកេរ្តិ៍ក្នុងវចនានុក្រមខ្មែរនេះ ចំពោះតែត្រង់ពាក្យថ្លែងអំពីគតិ ៩យ៉ាង ដែលបុរសជាប្តីត្រូវប្រតិបត្តិចំពោះស្ត្រីជាប្រពន្ធប៉ុណ្ណោះ, មិនមានសេចក្តីវែងណាស់ណាទេ, ដូចតទៅនេះគឺ កតមេហិ បញ្ចគតី- ហិ សាមិកា ភរិយាស- ង្គហាធម្មា ប្រែតាមអត្ថា-ធិប្បាយបាលី ។ ថាប្រុសឯណា នឹងមានភរិយា លោកឲ្យចេះក្តី ទាំងប្រាំចំពោះ សង្គ្រោះចិត្តស្រី ប្រពន្ធប្រក្រតី ដូចធម៌សម្តែង ។ បើប្តីឯណា ពុំកាន់កិរិយា ទាំងប្រាំនេះឯង ហៅប្តីទុជ៌ន ដួលន់ក្រៃលែង ចេះតែកំហែងចិត្តប្រពន្ធពិត ។ បើប្តីកាន់ច្បាប់ ទាំងប្រាំនេះខ្ជាប់ ហៅប្តីសុចរិត បម្រុងកិរិយា ដោយនាក្រមក្រឹត្យ្យ បសើរពេកពិត ឥតអ្វីផ្ទឹមឡើយ ។ អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ កុំមានកន្តើយ មានប្រពន្ធហើយជាសុខសម្រាន្ត ។ មួយគឺហៅប្តី ឲ្យប្រើសំដី នឹងប្រពន្ធមាន ពាក្យទន់ពីរោះ ស្មើស្មោះដោយក្សាន្ត សរសើរាប់អាន តាមសព្វវាចា ។ មួយគឺប្រពន្ធ ខុសធ្ងន់ស្រាលធ្ងន់ កុំជេរផ្តាសា ទាត់ធាក់ជៀលដំ ដូចខ្ញុំអាត្មា កុំស្តីដើមថា ឲ្យព្វសាយស័ព្ទ ។ មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្តាប់ ទាំងគ្រឿងអាហារ ជាការស្រីផ្គាប់ រៀបចំសម្រាប់ថែទាំរក្សា ។ មួយគឺកុំផ្ចង់ កុំខំតែប- ង្កើតកូនហើយថា ប្រពន្ធសុខចិត្ត ឲ្យគិតប្រាថ្នា រួសរកទ្រព្យា សម្រាប់ឲ្យផង ។ មួយគឺឲ្យចាប់ ស្រឡាញ់ឲ្យខ្ជាប់ កុំជិនណាយហោង បើមានប្រពន្ធ- ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង ឲ្យស្មើមុខឡើយ ។ សម្តែងសេចក្តី គ្រប់ប្រាំវិធី ចែងចប់ស្រេចហើយ ឲ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្ចង់កុំ

កន្តើយ ចោលច្បាប់បុរាណ ។ បើប្រុសឯណា ពុំផ្ចង់ចិន្តា ដូចធម៌ទូន្មាន នៅនឹង
ភរិយា គ្មានជាសុខសាន្ត ហិនហោចធនធាន ទាស់ទែងលែងគ្នា ។ ឯវិស័យចិត្ត អស់
ស្រីផងពិត មានប្តីប្រាថ្នា អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា នៅនាលោកិយ ។
បើខ្វះអំពើ- ណាមួយហើយតើ ប្រពន្ធថាប្តី ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី តូចចិត្តស្វាមី
អាក់អន់ពុំស្មោះ លោកឲ្យប្រុសផង គន់គិតសួនគ្រង ផ្ចង់ចិត្តសង្គ្រោះ- ប្រពន្ធឲ្យពិត
ដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះ- ចិត្តចូលមូលឯង ។ កុំគិតតែយក- ប្រពន្ធបាន
មក គ្រាន់ឱបប្រលែង បង្កើតតែកូន សោះសូន្យធនធេង លោកឲ្យគិតក្រែង
ដំណៀលនិន្ទា ។ ធម្មតាជាប្តី បានទ្រព្យធនអ្វី ឬយសសក្តា តែងនៅសុខសឹង- ទីពឹង
ផងគ្នា ព្រោះដ្បិតភរិយា កាន់ក្តីសុចរិត ។ អំពើច្នេះហោង ឲ្យអស់ប្រុសផង ចងចាំ
ក្នុងចិត្ត តាមធម៌ទូន្មាន គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រិត្យ ច្បាប់ច្បាស់តទៅ ។
អង្គអញរចនា សេចក្តីកាព្យា តាមច្បាប់ទុកនៅ ក្នុងព្រះបាលី សេចក្តីជ្រាលជ្រៅ ពុំ
ហ៊ានសៅដៅ លើកលែងផាយដាយ ។ ឧស្សាហ៍ខំប្រុង ប្រែរករើសក្នុង គម្ពីរនិកាយ
អដ្ឋកថា ដីកាបរិយាយ និបាតទាំងឡាយ មកផ្សំស្រដី ។ ជាច្បាប់ទុកត ដំណឹងតំណ
ដំណើរស្ត្រី ឲ្យជាក់ប្រាកដ ដោយបទបាលី គ្រាន់អស់ប្រុសស្រី រើសរៀនរកផ្លូវ ។
ច្បាប់នេះប្រសើរ ដំណឹងដំណើរ ទំនងនេះគួរ ជាច្បាប់ប្រាកដ ដោយបទត្រឹមត្រូវ
គួរយើងឥឡូវ ប្រតិបត្តិរក្សា ។ គួររៀនឲ្យស្ទាត់ ឲ្យចាំរត់មាត់ ដាក់ក្នុងចិន្តា គ្រាន់នឹង
ប្រិតប្រៀន បង្រៀនអាត្មា តាមដោយគាថា នេះឯងតទៅ ។ បែងចប់អភិប្រាយ
ដោយអត្ថបរិយាយ សូរេចថ្ងៃសៅរ៍ ប្រាំបីរោចឯ នាខែមាឃនៅ ឆ្នាំរកាត្រូវ នព្វស័ក
ស្រេចហោង ។៚

«ដកស្រង់ចេញពីវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត** ត្រង់ពាក្យថា «**ប្តី**» »

ភិក្ខុ ស្វាត សាលឿម